រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០២ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧/អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំង លោក **សុខ សោភ័ណ** អតីតទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋបារាំង ជាប្រធាននាយកដ្ឋានអឺរ៉ុប នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូនៈ

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៣...អនក្រ.ចក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

៚៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកវេជ្ជ. **William James Pigott** ដែលបានមកបំពេញបេសកកម្ម នៅប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៩៩ ហើយត្រូវចប់អាណត្តិ នៅចុងឆ្នាំ ២០០១ នេះ ដោយបានខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្ត និងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីជួយអភិវឌ្ឍន៍លើវិស័យសុខាភិបាល អោយមានការរីកចំរើន ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការពារ
~~~~~~~~~~
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

__មាត្រា១__ : ត្រូវបានបំពាក់ **មេដាយការពារ** តាមលំដាប់ថ្នាក់ ជូនដល់នាយទាហានតំបន់ប្រតិបត្តិការសឹករងសៀមរាប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ÷

ក-__មេដាយមាសការពារ__ :

១-វរសេនីយ៍ឯក ឃឹម ប៊ុនសុខ អត្តលេខ ០០០៩៧០ មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងសៀមរាប

២-វរសេនីយ៍ទោ រៀម ស្វះ អត្តលេខ ០០០៩៧៣ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងសៀមរាប

៣-វរសេនីយ៍ទោ គង់ ស៊ី អត្តលេខ ០០២៩៧៤ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងសៀមរាប

៤-វរសេនីយ៍ទោ ព្រឹម ទីះ អត្តលេខ ០០២៨៤៥ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងសៀមរាប
~~~~~~~~~~

៥-វរសេនីយ៍ទោ ឆេត រួន អត្តលេខ ០០១៨១៩ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង សៀមរាប

៦-វរសេនីយ៍ទោ យត់ សុផល អត្តលេខ ០០២៨៨៥ មេបញ្ជាការរង និងជានាយសេនាធិការ តំបន់ប្រតិបត្តិការសឹករងសៀមរាប

ខ-មេដាយប្អូនឆារខារ :

១-វរសេនីយ៍ត្រី ប៉ែន សុចត្ថិ អត្តលេខ ០០២៨៨៤ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង សៀមរាប

២-វរសេនីយ៍ត្រី នៅ ជា អត្តលេខ ០០៨២០០ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង សៀមរាប

៣-វរសេនីយ៍ត្រី សែម សារិន អត្តលេខ ០១០១៤៧ នាយរងសេនាធិការ តំបន់ប្រតិបត្តិការសឹករង សៀមរាប

៤-អនុសេនីយ៍ឯក ទិញ ឡឿន អត្តលេខ ០១០១៥១ មេបញ្ជាការ វរសេនាតូចលេខ ១ តំបន់ប្រតិបត្តិការសឹករងសៀមរាប

៥-អនុសេនីយ៍ឯក ចាន់ ថាវី អត្តលេខ ០១០១៤៦ មេបញ្ជាការ វរសេនាតូចលេខ ២ តំបន់ប្រតិបត្តិការសឹករងសៀមរាប

៦-អនុសេនីយ៍ឯក នឹម ប៊ុនធឿន អត្តលេខ ០១០១៥២ មេបញ្ជាការ វរសេនាតូចលេខ ៣ តំបន់ប្រតិបត្តិការសឹករងសៀមរាប

គ-មេដាយសំរិទ្ធឆារខារ :

១-អនុសេនីយ៍ឯក ឌុំ យ៉ាត អត្តលេខ ០១០១៤៥ នាយការិយាល័យទី១ តំបន់ប្រតិបត្តិការ សឹករងសៀមរាប

២-អនុសេនីយ៍ឯក ម៉ៅស សំអុល អត្តលេខ ០១០១៥៣ នាយការិយាល័យទី២ តំបន់ប្រតិបត្តិការ សឹករងសៀមរាប

៣-អនុសេនីយ៍ឯក ស៊ូ នី អត្តលេខ ០១០១៤៨ នាយការិយាល័យទី៤ តំបន់ប្រតិបត្តិការ សឹករងសៀមរាប

៤-អនុសេនីយ៍ឯក ម៉ឿង សាខន់ អត្តលេខ ០១០១៤៩ នាយការិយាល័យទី៥ តំបន់ប្រតិបត្តិការ សឹករងសៀមរាប

៥-អនុសេនីយ៍ឯក គង់ ព្រី អត្តលេខ ០១០១៦០ នាយការិយាល័យហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការ សឹករងសៀមរាប

42

៦-អនុសេនីយ៍ឯក អ៊ុង វឿន អត្តលេខ ០១៩១០០ នាយការិយាល័យជីវពល តំបន់ប្រតិបត្តិការសឹករងសៀមរាប

៧-អនុសេនីយ៍ឯក ទេវ សំបូរ អត្តលេខ ០១៧៩៣៨ នាយផ្នែកហិរញ្ញវត្ថុ តំបន់ប្រតិបត្តិការសឹករងសៀមរាប

៨-អនុសេនីយ៍ឯក ទ៉េះ គង់ អត្តលេខ ០១០១៩៤ មេបញ្ជាការសឹករងស្រុកជីក្រែង តំបន់ប្រតិបត្តិការ សឹករងសៀមរាប

៩-អនុសេនីយ៍ឯក ជុំ សាវី អត្តលេខ ០១០១៦៦ មេបញ្ជាការសឹករងស្រុកស្វាយលើ តំបន់ប្រតិបត្តិការសឹករងសៀមរាប

១០-អនុសេនីយ៍ឯក នួន ណាត់ អត្តលេខ ០១០១៩៧ មេបញ្ជាការសឹករងស្រុកសូទ្រនិគម តំបន់ប្រតិបត្តិការសឹករងសៀមរាប

១១-អនុសេនីយ៍ឯក ភ្ភា សុខុឌ្ឍៈរ៍ អត្តលេខ ០១០១៩៨ មេបញ្ជាការសឹករងស្រុកប្រាសាទបាគង តំបន់ប្រតិបត្តិការសឹករងសៀមរាប

១២-អនុសេនីយ៍ឯក ជា ផុន អត្តលេខ ០១០១៥៩ មេបញ្ជាការសឹករងស្រុកពួក តំបន់ប្រតិបត្តិការសឹករងសៀមរាប

១៣-អនុសេនីយ៍ឯក ឌឹម សុភារ អត្តលេខ ០១១៤៤៥ មេបញ្ជាការសឹករងស្រុកស្រីស្នំ តំបន់ប្រតិបត្តិការសឹករងសៀមរាប

១៤-អនុសេនីយ៍ឯក ឆាយ យ៉ុន អត្តលេខ ០១០១៦២ មេបញ្ជាការសឹករងស្រុកអង្គរជុំ តំបន់ប្រតិបត្តិការសឹករងសៀមរាប

១៥-អនុសេនីយ៍ឯក ម៉ិត ទិទិត្រ អត្តលេខ ០១០១៦៣ មេបញ្ជាការសឹករងស្រុកវ៉ារិន តំបន់ប្រតិបត្តិការ សឹករងសៀមរាប

១៦-អនុសេនីយ៍ឯក ធឹម សាទុធ អត្តលេខ ០១០១៦៤ មេបញ្ជាការសឹករងស្រុកអង្គរធំ តំបន់ប្រតិបត្តិការសឹករងសៀមរាប

១៧-អនុសេនីយ៍ឯក អួង រុន អត្តលេខ ០១០១៦៥ មេបញ្ជាការសឹករងស្រុកបន្ទាយស្រី តំបន់ប្រតិបត្តិការសឹករងសៀមរាប

១៨-អនុសេនីយ៍ទោ ជា ញ៉ិល អត្តលេខ ០១៩៥១៤ មេបញ្ជាការសឹករងស្រុកសៀមរាប តំបន់ប្រតិបត្តិកាសឹករងសៀមរាប

១៩-អនុសេនីយ៍ទោ ចាន់ សុផល អត្តលេខ ០១៨៥៣៥ នាយផ្នែកលេខាធិការដ្ឋាន តំបន់ប្រតិបត្តិការសឹករងសៀមរាប

៧០-អនុសេនីយ៍ទោ រាជ្ញ សុខរដ្ឋ អត្តលេខ ០១៧៥៣៩ នាយផ្នែកសុខាភិបាល តំបន់ប្រតិបត្តិការសឹករងសៀមរាប

៧១-អនុសេនីយ៍ទោ គង់ ហ៊ីត អត្តលេខ ០១៨៦៧៥ មេបញ្ជាការសឹករងស្រុកក្រឡាញ់ តំបន់ប្រតិបត្តិការសឹករងសៀមរាប

៧២-អនុសេនីយ៍ត្រី ឆង់ ឃួន អត្តលេខ ០៣៧១៦១ នាយការិយាល័យទី៣ តំបន់ប្រតិបត្តិការសឹករងសៀមរាប

មាត្រា ៣ ៖ រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគទ្រព្យធនផ្ទាល់ខ្លួន ជួយកសាង កុដិ ០១ ខ្នង មាន ២ ជាន់ ក្នុងវត្តសុវណ្ណក្លាសត្ថារាម ភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

ក_មេដាយមាសស្ថាបនាជាតិ

១-លោកឧត្តមសេនីយត្រី **ស៊ីន្ន គីរី** អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន និង លោកស្រី **ឈីន គីមស៊ាម** ថវិកាចំនួន ១០.៣៥០ USD

២-លោក **ទៅ ទ៊ា** និងលោកស្រី **ស៊ុំ កុឡាប** ថវិកាចំនួន ១០.៣០០ USD

ខ_មេដាយប្រាក់ស្ថាបនាជាតិ

-លោកវរសេនីយឯក **ខួន សុវណ្ណា** អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន និង លោកស្រី **សុខ ហួរ** ថវិកាចំនួន ៥.៣០០ USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..០៧...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនក្នុង និង ក្រៅប្រទេស ចំនួន ១៧ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា ក្នុងវត្តសាមគ្គីគិរីអម្ពវ័ន (ភ្នំស្រមោច) នៅឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយនាមខាងក្រោមនេះ ÷

ក - **មេដាយមាសស្ថាបនាជាតិ** :

១ - ឯកឧត្តម	**ម៉ែន**	**ស៊ីម៉ន**	នាយកទីចាត់ការគយ និង រដ្ឋាករ	ទឹកប្រាក់ ១៨.៧៥០ USD
២ - ឯកឧត្តម	**ឈី**	**ឈន់**	នៅភ្នំពេញ	ទឹកប្រាក់ ១៥.៦៧៣ USD
៣ - អ្នកស្រី	**ប្រាក់**	**គីមហាន**	នៅភ្នំពេញ	ទឹកប្រាក់ ១៥.២៥០ USD
៤ - លោក	**ឈី**	**ម៉ឿន**	នៅភ្នំពេញ	ទឹកប្រាក់ ១៣.៨៩២ USD

ខ - **មេដាយប្រាក់ស្ថាបនាជាតិ** :

១ - ឧបាសក	**សួស**	**តឹក**	នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ៧.៩៨០ USD
២ - លោក	**អ៊ុច**	**សាត**	នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ៧.៦៧៥ USD
៣ - លោកអាចារ្យ	**ទ្រី**	**សូត**	នៅភ្នំពេញ	ទឹកប្រាក់ ៦.៧៨៤ USD

គ - **មេដាយសំរឹទ្ធស្ថាបនាជាតិ** :

១ - ឧបាសិកា	**ចេង**	**ឡាច**	នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ៣.៧៩៨ USD
២ - លោកអាចារ្យ	**ថាវៈ**	**សុចិត្រា**	នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ២.៨៦៧ USD
៣ - ឧបាសក	**ខែម**	**សុន**	នៅសហរដ្ឋអាមេរិក	ទឹកប្រាក់ ២.៧៩៨ USD

៤ - ឧបាសិកា គង់ ម៉ុន នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ២.៧៥៦ USD
៥ - ឧបាសិកា ហេង សុន នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ២.៥៥៤ USD
៦ - លោក នាង ថិយ នៅខេត្តកំពត ទឹកប្រាក់ ២.៣៤០ USD
៧ - លោក ហង់ ហោម នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ១.៧៩៥ USD
៨ - ឧបាសិកា តាន់ អាប់ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ១.៥៧៨ USD
៩ - លោក គង ឈឿន នៅសហរដ្ឋអាមេរិក ទឹកប្រាក់ ១.២៧៦ USD
១០ - លោក ខៀវ ឈឿន នៅកំពង់សោម ទឹកប្រាក់ ១.២០០ USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០០២ .

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...០៧៧...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ**ជូនលោក ANDREW OLIVER SMITH ប្រធានអង្គការ AAH អង្គការប្រឆាំងគ្រោះអត់ឃ្លានខេត្តកំពង់ចាម ដែលបានធ្វើសកម្មភាព ០៤ ឃុំ តាមបណ្តោយមាត់ទន្លេ ឃុំទន្លេបិទ ឃុំជីរោទិ៍ ១ ឃុំបឹងព្រួល និង ឃុំពាមជីលាំង ក្នុងស្រុកត្បូងឃ្មុំខេត្តកំពង់ចាម ដោយចំណាយអស់ទឹកប្រាក់សរុប ២៤៨.២៨៧ ដុល្លារអាមេរិក ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០០២

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ នៃ ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចំនួន ០៥ រូប ដែលមានស្នាដៃល្អក្នុងការអនុវត្តន៍គំរោងអង្គការភូមិកុមារអន្តរជាតិ SOS ប្រចាំនៅកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ ÷

ក. មេដាយមាសការងារ :

១- លោក **កែវ សារកាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិង ហិរញ្ញវត្ថុ

២- លោក **ម៉ៅ សុទត្ថិ** អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ

៣- លោក **ឃួន វ៉ានីន** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង ជំនួយ

៤- លោក **ផាំ ទ៉ុកស៊ីន** តំណាងអង្គការភូមិកុមារអន្តរជាតិ ប្រចាំនៅកម្ពុជា

ខ. មេដាយប្រាក់ការងារ :

- លោក **ម៉ម ប៊ុនសុខ** អ្នកសំរបសំរួល

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....០.៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន តំណាងអង្គការភូមិកុមារអន្តរជាតិ SOS ចំនួន ០២ រូប និង មន្ត្រីកម្ពុជា ០២ រូប ដែលបានសហការ ទិញដី សង់ផ្ទះ សង់សាលារៀន និង ប្រមូលកុមារកំព្រា ក្រីក្រ ទុរគត មកចិញ្ចឹមអោយរៀនសូត្រ នៅទីក្រុងភ្នំពេញ និង ខេត្តសៀមរាប និង កសាងទីស្នាក់ការនៅភ្នំពេញ ចំណាយអស់ថវិកាសរុបចំនួន ២.៥៣៧.៥៣៥.២៤ ដុល្លារអាមេរិក ដូចមាន រាយនាមខាងក្រោមនេះ ÷

១-លោក	HELMUT KUTIN	ប្រធានអង្គការភូមិកុមារអន្តរជាតិ SOS
២-លោក	SIDDHARTHA KAUL	អគ្គលេខាធិការរងអង្គការភូមិកុមារអន្តរជាតិ SOS
៣-ឯកឧត្តម	**អ៊ិត សំហេង**	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា និង ជាប្រធានកិត្តិយសគណៈកម្មការភូមិកុមារ SOS កម្ពុជា

៤-ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា និង ជាប្រធានប្រតិបត្តិគណៈកម្មការភូមិកុមារ SOS កម្ពុជា

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២

ហ៊ុន សែន

កន្លែងទទួល
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា២
-រាជកិច្ច
-កាលប្បវត្តិ- ឯកសារ

/អ/

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:....១០...អនក្រ...បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនលោកមេឃុំ និង ជំទប់ នៃខេត្តបាត់ដំបងចំនួន ៩៧ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច កន្លងមក ដូចមានរាយនាមខាងក្រោមនេះ ÷

១-លោក **ព្រឹម ស៊ីន** មេឃុំ ទួលតាឯក
២-លោក **សុខ សាន្ត** មេឃុំ ព្រែកព្រះស្តេច
៣-លោក **ខៀវ សែ** មេឃុំ រតនៈ
៤-លោក **ឃិន ផាត** មេឃុំ ចំការសំរោង
៥-លោក **គឹម ឆន** មេឃុំ អូរចារ
៦-លោក **ប៊ុន តឿ** មេឃុំ ស្វាយប៉ោ
៧-លោក **ឯល សារ៉ែឡេស** មេឃុំ ស្លាកែត
៨-លោក **យិន សាខន** មេឃុំ ក្តុលដូនទាវ
៩-លោក **សុភ ឈឿក** មេឃុំ វត្តគរ

១០-លោក សន ពឿន	មេឃុំ អូរម៉ាល់
១១-លោក អោ លន់	មេឃុំ ភ្នំសំពៅ
១២-លោក យស សានិត	មេឃុំ ស្ទឹង
១៣-លោក ណយ ផល	មេឃុំ តាគ្រាម
១៤-លោក រី ឈាន	មេឃុំ ឈើទាល
១៥-លោក កុច ធឿន	មេឃុំ បាយដំរាំ
១៦-លោក សឿន ម៉ត	មេឃុំ កន្ទឺ២
១៧-លោក គុយ គឿន	មេឃុំ កន្ទឺ១
១៨-លោក ខិន ទ័ន	មេឃុំ ចែងមានជ័យ
១៩-លោក ខូច ស្វាង	មេឃុំ អន្លង់វិល
២០-លោក សេត សើ	មេឃុំ នរា
២១-លោក ទ័រ សុវណ្ណ	មេឃុំ តាប៉ុន
២២-លោក ខិត ហឿន	មេឃុំ រកា
២៣-លោក សុខ ឈួន	មេឃុំ កំពង់ព្រះ
២៤-លោក សំ អ៊ត	មេឃុំ រាំងកេសី
២៥-លោក អ៊ុត ពឿត	មេឃុំ អូរដំបង១
២៦-លោក ឈួម ទី	មេឃុំ អូរដំបង២
២៧-លោក អ៊ឹម ស្វាង	មេឃុំ វត្តតាមិម
២៨-លោក អ៊ុំ គីមសោន	មេឃុំ កំពង់ព្រៀង
២៩-លោក ឯក តាន	មេឃុំ សំរោងក្នុង
៣០-លោក ម៉ៅ សេង	មេឃុំ ព្រែកខ្ពប
៣១-លោក សាត សឿន	មេឃុំ ព្រែកហ្លួង
៣២-លោក សាំង ធឿន	មេឃុំ ពាមឯក
៣៣-លោក សេង យី	មេឃុំ ព្រែកនរិន្ទ
៣៤-លោក ឈន លាង	មេឃុំ ព្រែកចាស់
៣៥-លោក ព្រាប ព្រឿង	មេឃុំ កោះជីវាំង
៣៦-លោក គង់ លីម	មេឃុំ ជ្រៃ
៣៧-លោក ម៉ង ណាច់	មេឃុំ អូរតាគី
៣៨-លោក ជុំ ហ៊ី	មេឃុំ គោគឃ្មុំ

៣៩-លោក សាន ថា	មេឃុំ បន្ទាយត្រែង
៤០-លោក ខ៊ែត នឹម	មេឃុំ ជ្រោយស្តៅ
៤១-លោក យូ សឿម	មេឃុំ រូងជ្រៅ
៤២-លោក ឡុក ហឿន	មេឃុំ តាម៉ឺន
៤៣-លោក អ៊ី គង់	មេឃុំ តាពូង
៤៤-លោក ជុំ អ៊ឹម	មេឃុំ បឹងព្រីង
៤៥-លោក មល់ រួន	មេឃុំ អន្លង់រុន
៤៦-លោក ស្រី សាម៉ុន	មេឃុំ មោង
៤៧-លោក អ៊ុក សារ៉េម	មេឃុំ កកោះ
៤៨-លោក ឈាង ឆាត	មេឃុំ ព្រៃតូច
៤៩-លោក ឆែត សឿត	មេឃុំ ជ្រៃ
៥០-លោក ពុយ សាវឌន	មេឃុំ ឫស្សីក្រាំង
៥១-លោក សូរ សៀង	មេឃុំ ព្រៃត្រឡាច
៥២-លោក ឌឿក មាឃ	មេឃុំ ព្រែកជីក
៥៣-លោក ឆឿក ឆឿម	មេឃុំ របស់មង្គល
៥៤-លោក មួង ឆុច	មេឃុំ តាលាស់
៥៥-លោក ជោត ជៀន	មេឃុំ តារ
៥៦-លោក អិន ទ្រី	មេឃុំ ព្រៃស្វាយ
៥៧-លោក ឡុង ម៉ៅ	មេឃុំ ខ្នាចរមាស
៥៨-លោក តាប់ គោ	មេឃុំ បវេល
៥៩-លោក រស់ គួ	មេឃុំ អំពិលប្រាំដើម
៦០-លោក រស់ ឈាន	មេឃុំ ក្តុលតាហែម
៦១-លោក ឡុច សារឿន	មេឃុំ ព្រៃខ្ពស់
៦២-លោក ឆឿង សារ៉េម	មេឃុំ ល្វា
៦៣-លោក អឿន ខៀង	មេឃុំ ក្តុលតាហែម (មេឃុំចាស់)
៦៤-លោក ឥល សារី	មេឃុំ ធិបតី
៦៥-លោក ហែម សំអុល	មេឃុំ តាសក្រឡ
៦៦-លោក សរ ទិចិត្រ	មេឃុំ ហប់
៦៧-លោក ភុក លីទ	មេឃុំ ព្រះផុស

៦៨-លោក អ៊ុក សារឿន មេឃុំ ឆ្កាល់មាន់

៦៩-លោក ចិន សំអន មេឃុំ ដូនបា

៧០-លោក ម៉ែន ម៉ា មេឃុំ ស្តៅ

៧១-លោក ផន សុផល មេឃុំ អណ្តើកហែប

៧២-លោក ទឹង យី មេឃុំ ត្រែង

៧៣-លោក ឃ៉ោល គី មេឃុំ ផ្លូវមាស

៧៤-លោក នួន សុគន្ធ មេឃុំ សំឡូត

៧៥-លោក ប៊ូ ឆាន់ មេឃុំ ស៊ុង

៧៦-លោក ជួន ផេង មេឃុំ តាសាញ

៧៧-លោក ងឹង ហ៊ិន មេឃុំ អូរសិរិល

៧៨-លោក ជួន សាលឿន មេឃុំ មានជ័យ

៧៩-លោក ម៉ែន ចឹម មេឃុំ កំពង់ល្ពៅ

៨០-លោក ជួន ដី មេឃុំ តាតោក

៨១-លោក ទង់ គួរ មេឃុំ កំរៀង

៨២-លោក រស់ ភប មេឃុំ តាក្រី

៨៣-លោក ឈឹម សឿន មេឃុំ អូរដា

៨៤-លោក សុខ ឆាវ មេឃុំ តាសែន

៨៥-លោក ថោង ញ៉ើន ជំទប់លេខ១

៨៦-លោក សៅ ប៊ុនឆន ជំទប់លេខ១

៨៧-លោក នុត សាត មេឃុំ ពេជចិន្តា

៨៨-លោក ចាប ម៉ោញ មេឃុំ បារាំងធ្លាក់

៨៩-លោក ឆ៊ិន ទុំ មេឃុំ អូររំដួល

៩០-លោក ម៉ែន ជឿន មេឃុំ ភ្នំព្រឹក

៩១-លោក ឡុង គីមហ៊ាង មេឃុំ ចក្រី

៩២-លោក ឡឿក ហ៊ែល មេឃុំ តាស្តា

៩៣-លោក ស៊ិន ស៊ីន មេឃុំ ជ្រៃសីមា

៩៤-លោក កែវ ញៀន មេឃុំ សំពៅលូន

៩៥-លោក សួន សែន មេឃុំ សន្តិភាព

៩៦-លោក ឡៀង អុំ មេឃុំ សិរីមានជ័យ

៩៧-លោក **សួន គង់** មេឃុំ អង្គរបាន

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ៨ ៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា២
-រាជកិច្ច
-កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ជូនសប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ០៣ រូប ដែលបានឧបត្ថម្ភគ្រែពេទ្យចំនួន ៧៣ គ្រែ និងបរិក្ខារដំណេកមាន ពូក មុង ខ្នើយ និងកំរាលពូក សរុបទឹកប្រាក់ចំនួន ៥.៤៧៥ ដុល្លារអាមេរិក សំរាប់អ្នកជំងឺក្នុងមន្ទីរពេទ្យខេត្តកំពត ដូចមានរាយនាមខាងក្រោម ÷

១.- ឧបាសក **យិត សេខ** ឧបាសិកា **ធ្លាក់ ចាន់ផន** ទឹកប្រាក់ ២.៣៧៥ USD

២ - លោក **ឃឹម ផន** អ្នកស្រី **ហ៊ិម សុន** ទឹកប្រាក់ ១.៥៥០ USD

៣ - ឧបាសិកា **ឌន ឃន** ទឹកប្រាក់ ១.៥៥០ USD

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ០០៦ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០២

ប្រកាសស្តីពីការទូទាត់
ការដេញថ្លៃកូតា ការបង់កំរៃនិដ្ឋាការ ការបង់សោហ៊ុយរដ្ឋបាល ក្នុងការស្នើសុំវិញ្ញាបនបត្រប្រភពដើម និងវិក័យបត្រពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ, ៥៤អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១: គ្រប់រោងចក្រកាត់ដេរ រោងចក្រស្បែកជើង រោងចក្រផលិតកាបូបទាំងអស់ ត្រូវទូទាត់ជូនក្រសួងពាណិជ្ជកម្ម (គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ) ជាមូលប្បទានប័ត្រឆូត (Crossed Cheques) នូវការដេញថ្លៃកូតា (Auctioned quota) ការបង់កំរៃទិដ្ឋាការនាំចេញទៅកាន់សហរដ្ឋអាមេរិក (Export Visa fees to USA) ការបង់កំរៃនាំចេញទៅកាន់សហគមន៍អ៊ឺរ៉ុប និងក្រៅពីសហគមន៍អ៊ឺរ៉ុប (Export fees to EU & Non EU) ការបង់សោហ៊ុយរដ្ឋបាល ក្នុងការស្នើសុំវិញ្ញាបនប័ត្រប្រភពដើម និងវិក័យប័ត្រពាណិជ្ជកម្ម (Administration fees) និងការបង់សោហ៊ុយរដ្ឋបាលក្នុងការស្នើសុំ អាជ្ញាប័ណ្ណនាំចេញ (Export Licence fees) ។

ប្រការ ៩ : បទបញ្ញត្តិទាំងឡាយដែលជាប់ទាក់ទិនដល់រូបភាពទូទាត់ថ្លៃកូតាផ្សេងទៀត ដែលបានប្រកាសឱ្យប្រើកន្លងមក មានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១៦ : នាយកខុទ្ទកាល័យ, អគ្គនាយកបច្ចេកទេស, អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ, ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ប្រធាននាយកដ្ឋានរដ្ឋបាល, ផលិតករសំលៀកបំពាក់ និងសមាជិកគណៈកម្មការគ្រប់គ្រងកូតានាំចេញ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ទីកន្លែងទទួល

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

Clever student

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ០៤ អយក.សជណ

សេចក្តីណែនាំ

ស្តីពីការរៀបចំថ្នាក់សិស្សពូកែនៅតាមគ្រឹះស្ថានមធ្យមសិក្សា និង ការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

***

<u>យោង</u> : អនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០០ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ។

ដើម្បីចូលរួមពង្រឹង និងលើកកំពស់គុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំពីការរៀបចំថ្នាក់សិស្សពូកែ និងការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកមធ្យមសិក្សា តាមខ្លឹមសារដូចខាងក្រោម ៖

១_<u>ថ្នាក់សិស្សពូកែតាមគ្រឹះស្ថានមធ្យមសិក្សារបស់ខេត្ត_ក្រុង</u> :

_នៅរាល់ដើមឆ្នាំសិក្សា គ្រឹះស្ថានមធ្យមសិក្សានីមួយៗ គប្បីរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា តាមកំរិតថ្នាក់នីមួយៗទាំងនៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ តាមលទ្ធភាពជាក់ស្តែងដែលអាចធ្វើបាន ។

_ថ្នាក់សិស្សពូកែតាមគ្រឹះស្ថានមធ្យមសិក្សានីមួយៗ អាចជ្រើសរើស និង រៀបចំតាមគំនិតច្នៃប្រឌិតផ្ទាល់របស់គ្រឹះស្ថានមធ្យមសិក្សាសាមី ទោះតាមរូបភាពណាក៏ដោយ ។

_ចំនួនសិស្សតាមថ្នាក់សិស្សពូកែគប្បីរៀបចំក្នុងចំនួនមួយសមរម្យ និងតាមលទ្ធភាពជាក់ស្តែង ។

_គ្រូដែលបង្រៀនថ្នាក់សិស្សពូកែ គប្បីរកគ្រូដែលមានបទពិសោធន៍ និង ត្រូវបង្រៀន តាមរបបម៉ោងកំនត់ ធម្មតារបស់គ្រូបង្រៀន ។

_ការសំរេចអោយឡើងថ្នាក់សិស្សពូកែខ្ពស់ជាងបន្តបន្ទាប់ ការជ្រើសរើសសិស្សពូកែបំពេញបន្ថែម និងការបញ្ជូនអោយទៅរៀនថ្នាក់ធម្មតាវិញជាសមត្ថកិច្ចរបស់គ្រឹះស្ថានមធ្យមសិក្សាផ្ទាល់ ដោយឈរលើលក្ខណៈវិនិច្ឆ័យមួយដែលជាគំនិតផ្តួចផ្តើមរបស់សាលារៀន ។

២_<u>សិស្សពូកែប្រចាំខេត្ត_ក្រុង</u> :

នៅដើមខែ មេសា គ្រប់ខេត្ត_ក្រុង គប្បីធ្វើការប្រលងជ្រើសរើសសិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ថ្នាក់ទី ៩ និងទី ១២ តាមលទ្ធភាពនិងគំនិតច្នៃប្រឌិតផ្ទាល់ ដែលក្នុងមួយមុខវិជ្ជា និងមួយកំរិតថ្នាក់តាមចំនួនដែលបានកំនត់ក្នុងតារាងបំនែងចែកជូនភ្ជាប់មកជាមួយនេះ ។

ចំពោះសិស្សថ្នាក់ទី ៩ និងទី ១២ នៃគ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅឯកជនក៏ត្រូវបានផ្តល់បេក្ខភាពប្រលងសិស្សពូកែដូចគ្រឹះស្ថានមធ្យមសិក្សាចំនេះទូទៅសាធារណៈដែរ ។

ដោយឡែកវិទ្យាល័យអនុវត្ត ត្រូវបានអោយទៅចូលរួមប្រលងជ្រើសរើសសិស្សពូកែថ្នាក់ក្រុង ជាមួយគ្រឹះស្ថានមធ្យមសិក្សានានាក្រោមឱវាទមន្ទីរអប់រំ យុវជន និង កីឡារាជធានីភ្នំពេញ ។

ប្រធានវិញ្ញាសាប្រលងជ្រើសរើសសិស្សពូកែតាមខេត្ត_ក្រុង ជាសមត្ថកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងសាមីជាអ្នកចាត់ចែង ។

៣_<u>ការប្រលងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងប្រទេស</u> :

Clever student

ពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ តទៅថ្ងៃបន្ទាប់ ក្រសួងអប់រំ យុវជន និង កីឡា នឹងរៀបចំប្រលងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងប្រទេសថ្នាក់ទី ៩ និងទី ១២ ផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ដែលមានកាលបរិច្ឆេទកំណត់ដូចខាងក្រោម៖

ថ្ងៃទី ២៣ ឧសភា ២០០២: ពីម៉ោង ៧ និង ៣០ នាទី ដល់ម៉ោង ១០ និង ៣០ នាទី
គណិតវិទ្យា អក្សរសិល្ប៍ខ្មែរ រូបវិទ្យា សំរាប់ថ្នាក់ទី៩ និងទី១២ ។

ថ្ងៃទី ២៤ ឧសភា ២០០២ : ពីម៉ោង ៧ និង ៣០ នាទី ដល់ម៉ោង ៩ និង ៣០ នាទី
វប្បធម៌ទូទៅ សំរាប់ថ្នាក់ទី ៩ និងទី ១២ ។

ថ្ងៃទី ២៥ ឧសភា ២០០២ : ពីម៉ោង ៧ និង ៣០ នាទី ដល់ម៉ោង ១០ និង ៣០ នាទី
គណិតវិទ្យា អក្សរសិល្ប៍ខ្មែរ រូបវិទ្យា សំរាប់ថ្នាក់ទី៩ និងទី១២ ។

ប្រធានវិញ្ញាសាប្រលងជ្រើសរើសជ័យលាភីសិស្សពូកែទូទាំងប្រទេសចេញដោយក្រសួងអប់រំ យុវជននិងកីឡា ហើយការប្រលងនឹងប្រព្រឹត្តទៅនៅ វិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញទាំងវិញ្ញាសាសរសេរ និងកំណែ ។

៤_សំណុំលិខិតរបស់បេក្ខជនសិស្សពូកែទូទាំងប្រទេស :

ក្រោយពីបានធ្វើការប្រលងជ្រើសរើសសិស្សពូកែនៅតាមខេត្ត_ក្រុងរៀងខ្លួនរួចហើយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុង ត្រូវបញ្ជូនបញ្ជីរាយនាមបេក្ខភាពសិស្សពូកែតាមផ្នែក និងតាមកំរិតថ្នាក់ ព្រមទាំងពាក្យសុំប្រលងសិស្សពូកែ (គំរូជូនភ្ជាប់) ចំនួនមួយច្បាប់ សលាកប័ត្រឯកត្តជនបេក្ខជនសិស្សពូកែទូទាំងប្រទេសទំហំ (២១ស.ម×១៥ស.ម)ចំនួនពីរច្បាប់ (គំរូជូនភ្ជាប់) និងរូបថតចំពីមុខទំហំ ៤ស.ម × ៦ស.ម ចំនួនបីសន្លឹក ទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ) អោយបានមុនថ្ងៃទី ០១ ខែ ឧសភា ២០០២ ។

បេក្ខជនសិស្សពូកែទូទាំងប្រទេសអាចជ្រើសរើសបានតែមួយមុខវិជ្ជាប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗ ត្រូវធ្វើការប្រលងជាបីពេល : មុខវិជ្ជាដែលខ្លួនបានជ្រើសរើសពីរពេល និងមុខវិជ្ជាវប្បធម៌ទូទៅមួយពេល ។

៥_ការមកដល់ភ្នំពេញរបស់បេក្ខជនសិស្សពូកែ :

បេក្ខជនសិស្សពូកែទូទាំងប្រទេស និងគ្រូដឹកនាំសិស្សពូកែ ត្រូវមកដល់មណ្ឌលប្រលង « មហាវិទ្យាល័យគរុកោសល្យ » នៅថ្ងៃទី ២២ ឧសភា ២០០២ វេលាម៉ោង ១៤ គត់ ដើម្បីប្រារព្ធពិធីបើកការប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ។

ចំពោះការចំណាយលើមធ្យោបាយធ្វើដំណើរទៅមករវាងខេត្ត_ក្រុង និងភ្នំពេញ មធ្យោបាយធ្វើដំណើរទៅមករវាងកន្លែងស្នាក់នៅ និងមណ្ឌលប្រលង ការស្នាក់នៅ ការហូបចុកទាំងបេក្ខជនសិស្សពូកែ និងគ្រូដឹកនាំជាបន្ទុករបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ក្រសួងអប់រំ យុវជន និង កីឡា សង្ឃឹមថា លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត_ក្រុង នឹងផ្សព្វផ្សាយសេចក្តីណែនាំនេះបានជ្រួតជ្រាបដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជនក្នុងខេត្ត_ក្រុង ព្រមទាំងអនុវត្តសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ , ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ទឹម_សិដ្ឋ

កន្លែងទទួល :
_ទីស្តីការគណៈរដ្ឋមន្ត្រី
_ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
« ដើម្បីសូមជ្រាបជាពត៌មាន»
_គ្រប់សាលាខេត្ត_ក្រុង
« ដើម្បីសូមជ្រាបជាពត៌មាន និងជួយឧបត្ថម្ភ»
_គ្រប់អង្គភាពក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និងកីឡា
« ដើម្បីជាពត៌មាន»
_គ្រប់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុង
_វិទ្យាល័យ អនុវត្ត
« ដើម្បីអនុវត្ត»
_កាលប្បវត្តិ_ឯកសារ_ នា. មធទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

ពាក្យសុំចុះឈ្មោះប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស

ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យា

☆☆☆

ខ្ញុំបាទ "នាងខ្ញុំ" ឈ្មោះ ...."ឈ្មោះជាអក្សរពុម្ពឡាតាំង"...............................

ភេទ.......ជនជាតិ.........សញ្ជាតិ.........កើតថ្ងៃទី.......ខែ..........ឆ្នាំ១៩........នៅឃុំ"សង្កាត់"..................

ស្រុក"ខណ្ឌ"..............................ខេត្ត"ក្រុង"..............................បងប្អូនបង្កើតចំនួន.........នាក់ ។

ឪពុកឈ្មោះ................................មុខរបរសព្វថ្ងៃ...

ម្តាយឈ្មោះ................................មុខរបរសព្វថ្ងៃ...

ជាសិស្សថ្នាក់ទី.........នៃវិទ្យាល័យ ឬអនុវិទ្យាល័យ...

ទីលំនៅបច្ចុប្បន្ន...

សូ ម គោ រ ព ជូ ន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

<u>តាមរយ</u> : - លោកប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង..................................

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាអនុញ្ញាតចាត់អោយចុះឈ្មោះខ្ញុំបាទ "នាងខ្ញុំ" ក្នុងបញ្ជីបេក្ខជនប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេស សម័យប្រលងថ្ងៃទី........ខែ...........ឆ្នាំ ២០០២ នៅមណ្ឌល.........................ដោយជ្រើសរើសយកមុខវិជ្ជា..........................ដោយអនុគ្រោះ ។

សូមជូនភ្ជាប់មកជាមួយនូវ

១-សលាកប័ត្រឯកត្តជន ទំហំ ១៥ស.ម × ២១ស.ម មានបិទរូបថត ៤×៦ ចំនួន ០២ ច្បាប់

២-រូបថត ថតថ្មី " ថតចំពីមុខ ទំហំ ៤×៦ " .... ចំនួន ០៣ សន្លឹក

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តា ទទួលនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំបាទ "នាងខ្ញុំ" ។

ធ្វើនៅ................ថ្ងៃទី........ខែ..........ឆ្នាំ ២០០

ហត្ថលេខា និង ឈ្មោះ

Clever student

សលាកបត្រឯកត្តជន បេក្ខជនសិស្សពូកែទូទាំងប្រទេស

បិទ
រូបថត
៤×៦

គោត្តនាម_នាម.............................ឈ្មោះជាអក្សរពុម្ពឡាតាំង.............................
ភេទ :..................ជនជាតិ........................សញ្ជាតិ..........................
កើតថ្ងៃទី :................ខែ.................ឆ្នាំ.......................................
នៅឃុំ_សង្កាត់....................ស្រុក_ខណ្ឌ..................ខេត្ត_ក្រុង................
ជាសិស្សថ្នាក់ទី :..........នៃវិទ្យាល័យ បូអនុវិទ្យាល័យ.......................................
ចំនួនបងប្អូនបង្កើត ....នាក់ និងជាកូនទី..........នៅក្នុងគ្រួសារ ។
ជ្រើសរើសយកមុខវិជ្ជា :...
ឪពុកឈ្មោះ :...មុខរបរ...
ម្តាយឈ្មោះ :...មុខរបរ...
អាស័យដ្ឋានបច្ចុប្បន្នរបស់បេក្ខជន :...
ប្រលងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងរូបវិទ្យាសម័យប្រលង :....................
មណ្ឌលប្រលង :..................................លេខបន្ទប់ :...........លេខតុ :....................

ធ្វើនៅ...............ថ្ងៃទី.........ខែ...........ឆ្នាំ ២០០

ហត្ថលេខា និង ឈ្មោះបេក្ខជន

<u>កំនត់សំគាល់</u> :

ត្រូវសរសេរបញ្ជាក់អោយបានច្បាស់ពីមុខរបរ
ឪពុកម្តាយ និងទីកន្លែងប្រកបមុខរបរ ។

[illegible]	[illegible]	[illegible]						[illegible]	[illegible]	[illegible]
		គណិតវិទ្យា	រូបវិទ្យា	អក្សរសាស្ត្រខ្មែរ	គណិតវិទ្យា	[illegible]	[illegible]			
1	ភ្នំពេញ	13	13	13	21	21	21	2	104	រួមទាំងវិ_អនុវត្ត
2	កណ្ដាល	8	8	8	7	7	7	2	47	
3	កំពង់ចាម	8	8	8	6	6	6	2	44	
4	បាត់ដំបង	6	6	6	5	5	5	2	35	
5	តាកែវ	6	6	6	6	6	6	2	38	
6	ព្រៃវែង	5	5	5	5	5	5	2	32	
7	សៀមរាប	3	3	3	3	3	3	1	19	
8	បន្ទាយមានជ័យ	3	3	3	3	3	3	1	19	
9	ពោធិសាត់	2	2	2	2	2	2	1	13	
10	កំពង់ឆ្នាំង	2	2	2	2	2	2	1	13	
11	កំពង់ធំ	3	3	3	3	3	3	1	19	
12	កំពត	4	4	4	3	3	3	1	22	
13	កំពង់ស្ពឺ	3	3	3	2	2	2	1	16	
14	ស្វាយរៀង	4	4	4	3	3	3	1	22	
15	ក្រចេះ	1	1	1	1	1	1	1	7	
16	ក្រុងព្រះសីហនុ	1	1	1	1	1	1	1	7	
17	ក្រុងកែប	1	1	1	1	1	1	1	7	
18	ក្រុងប៉ៃលិន	1	1	1	1	1	1	1	7	
19	កោះកុង	1	1	1	1	1	1	1	7	
20	ស្ទឹងត្រែង	1	1	1	1	1	1	1	7	
21	ព្រះវិហារ	1	1	1	1	1	1	1	7	
22	មណ្ឌលគិរី	1	1	1	1	1	1	1	7	
23	រតនគិរី	1	1	1	1	1	1	1	7	
24	ឧត្ដរមានជ័យ	1	1	1	0	0	0	1	4	
	សរុប	80	80	80	80	80	80	30	510	

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ......001/ប្រ.ក...... ក.អ.ជ

ភ្នំពេញ, ថ្ងៃទី..០៣..ខែ...មករា...ឆ្នាំ200..២

ប្រកាស
ស្តីពីការតែងតាំងមន្ត្រី បំរើការងារក្នុងអង្គភាពគាំទ្រគំរោង
សំរាប់អនុវត្តគំរោង
ក្នុងក្របខ័ណ្ឌឥណទាននៃមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស / រកម / ០១៩៦ / ១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើនូវច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ / បក ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញសេចក្តីសំរេចលេខ ១៧៩១ សសរ / អបជ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកភារកិច្ច និង ការកំណត់របៀបរបបធ្វើការរបស់ថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ
- AIDE MEMORIE របស់ IFAD Appraisal Mission ជាមួយក្រសួងពាក់ព័ន្ធ និង ភ្នាក់ងារជាដៃគូ ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០០ ។
- យោងតំរូវការចាំបាច់
- យោងលទ្ធផលរបស់គណៈកម្មការជ្រើសរើស ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០១

សំរេច

<u>ប្រការ១</u> : តែងតាំង **លោក កែច ទិសិដ្ឋ** ជាមន្ត្រីហិរញ្ញវត្ថុ ដើម្បីបំរើការងារក្នុងអង្គភាពគាំទ្រគំរោង សំរាប់អនុវត្តគំរោងអភិវឌ្ឍន៍សហគមន៍មូលដ្ឋានជនបទ ក្នុងខេត្តកំពង់ធំ និង ខេត្តកំពត ក្នុងក្របខ័ណ្ឌឥណទាន នៃមូលនិធិអន្តរជាតិសំរាប់អភិវឌ្ឍន៍កសិកម្ម ដែលមានស្នាក់ការនៅក្រសួងអភិវឌ្ឍន៍ជនបទ ។

<u>ប្រការ២</u> : សាមីជនដូចមានចែងក្នុងប្រការ១ មានភារកិច្ចទទួលខុសត្រូវ ក្នុងការអនុវត្តការងារក្នុងអង្គភាពគាំទ្រគំរោងសំរាប់អនុវត្តគំរោងក្នុងក្របខ័ណ្ឌឥណទាន នៃមូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម ដូចមានចែងក្នុងឯកសារគំរោង ។

<u>ប្រការ៣</u> : រាល់សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីសំរេចនេះ ចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៤</u> : អគ្គនាយកទាំងពីរ អគ្គាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋាន ក្រោមឳវាទក្រសួង គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ និង ខេត្តកំពត គ្រប់មន្ទីរពាក់ព័ន្ធ នៃខេត្តទាំងពីរ និងសាមីជនដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

លី ធុជ

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារសីលា
- សាលាខេត្តកំពង់ធំ និង កំពត
- មន្ទីរពាក់ព័ន្ធខេត្តទាំងពីរ
- អង្គការ IFAD,GTZ,WFP&AusAID
  " ដើម្បីជូនជ្រាប "
- ដូចមានចែងក្នុងប្រការ៣
  " ដើម្បីអនុវត្ត "
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ,ថ្ងៃទី០៣ ខែមករា ឆ្នាំ ២០០២...

ក្រសួងធម្មការ និង សាសនា

លេខ........ក.ធ.ស

សេចក្តីសំរេច

ស្តីពីការអនុញ្ញាតច្បាប់សាងសង់វិហារឥស្លាម

ភូមិស្ទឹងវែង ឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ ខេត្តកោះកុង

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ . ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល .
- បានឃើញព្រះរាជក្រម លេខ នស.ករម ០១៩៦-១៩ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក . ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងចំណារឯកភាពរបស់ឯកឧត្តមអភិបាលរងទី2ខេត្តកោះកុង លេខ ១១២៧ ខកទ., ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០១
- យោងសំណើសុំច្បាប់អនុញ្ញាតសាងសង់វិហារឥស្លាម ភូមិស្ទឹងវែង ឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ ខេត្តកោះកុង , ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០១ ។

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យសាងសង់វិហារឥស្លាមមួយស្ថិតនៅ ភូមិស្ទឹងវែង ឃុំស្ទឹងវែង ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ។

ប្រការ ២ : វិហារនេះត្រូវបានអនុញ្ញាតឱ្យសាសនិកឥស្លាម ធ្វើជាទីកន្លែងគោរពប្រតិបត្តិតាមជំនឿសាសនាឥស្លាម និង អនុវត្ត ឱ្យបានត្រឹមត្រូវតាមគម្ពីរគួរអាន និង ហាទ់ទេស នៃសាសនាឥស្លាម ។

ប្រការ ៣ : គណៈអ៊ីមាំ និង សាសនិកឥស្លាមចំណុះវិហារនេះ ត្រូវគោរពឱ្យបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជានិងបទបញ្ញតិទាំងឡាយរបស់ក្រសួងធម្មការ និងសាសនា មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព ជំនឿសាសនាដ៏ទៃនិងសណ្តាប់ធ្នាប់សង្គម ព្រមទាំងធ្វើការទំនាក់ទំនងឱ្យបានល្អជាមួយអាជ្ញាធរមូលដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ ។

ប្រការ ៤ : អគ្គនាយកដ្ឋានធម្មការ "នាយកដ្ឋានពាហិរសាសនា" មន្ទីរធម្មការ និង សាសនា ខេត្តកោះកុង ការិយាល័យធម្មការនិងសាសនាស្រុកស្មាច់មានជ័យ គណៈអ៊ីមាំវិហារ និងសាសនិកឥស្លាម ភូមិស្ទឹងវែង ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៥ : សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចំលងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្តកោះកុង
- សាលាស្រុកស្មាច់មានជ័យ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៤

"ដើម្បីសហការអនុវត្ត"

ឯកសារ កាលប្បវត្តិ

ជា_សាវឿន